ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,

Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN Saray**
ជាតំណាងទី ១ និង
ជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
ជាតំណាងទី ២ និង
ជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហិរញ្ញិក
និងជានាយក **CCPCR**

លោក **យៀង វណ្ណា**
**Mr. YEANG Vanna**
ប្រធាន **KKKHRA**

លោក **ជីវ យូម៉េង**
**Mr. CHIV You Meng**
ប្រធាន **KYA**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**
នាយិកា **LAC**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
ប្រធាន **PDP Center**

លោក **ទូច ទុម្ព**
**Mr. TOUCH Tum**
នាយក **VIGILANCE**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

នាយិកា **CWCC**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**
**ឥស្សរជន**

លោក **សឺន សែត**
**Mr. SEN Set**
**ឥស្សរជន**

ស.ប្រ.ក.៣/លេខ ០២/០៨ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មានស្តីពី
# លទ្ធផលនៃការអង្កេត នៅលើទូរទស្សន៍ជាតិកម្ពុជា (ទទក)

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨*

ការអង្កេតទៅលើទូរទស្សន៍ជាតិកម្ពុជាពីខែតុលា ឆ្នាំ២០០៧ ដល់ខែមករា [១] ឆ្នាំ២០០៨ បង្ហាញថា **ព័ត៌មាននយោបាយ** [២] **នៅក្នុងទូរទស្សន៍ជាតិកម្ពុជាមិនមានការប្រែប្រួលខុសប្លែកពីរបាយការណ៍អង្កេតមុនៗ**នោះទេ ដោយព័ត៌មានវិជ្ជមានសម្រាប់តែគណបក្សកាន់អំណាចប៉ុណ្ណោះ។ ជាមួយគ្នានេះ ការអង្កេតក៏ឃើញដែរថា គណបក្ស **ហ៊្វុនស៊ិនប៉ិច** និងគណបក្ស **សមរង្ស៊ី** ត្រូវបានព្ញដ៏តិចតួចនៅក្នុងរយៈពេលអង្កេតនេះ។

ទទក មិនមែនជាទូរទស្សន៍តែមួយគត់ ក្នុងចំណោមទូរទស្សន៍ទាំងអស់នៅកម្ពុជា ដែលបានផ្សាយលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជានោះទេ ទូរទស្សន៍ឯកជន និងទូរទស្សន៍ពាក់កណ្តាលរដ្ឋឯកជនផ្សេងទៀត ក៏បានផ្សាយលម្អៀងយ៉ាងខ្លាំងផងដែរ។

ខាងក្រោមបង្ហាញពីរបាយការណ៍អង្កេតទៅលើ ទទក:

**៩០%** (ស្មើនឹង **៣.៧៤៥ លើក**) នៃព័ត៌មាននយោបាយគឺលើកឡើងពីការងារ និងសកម្មភាពរបស់រាជរដ្ឋាភិបាល ដែលភាគច្រើនគឺទាក់ទងនឹងការចុះទៅមូលដ្ឋានជួបប្រជាពលរដ្ឋ ចែកអំណោយ និងសួរសុខទុក្ខជាដើម។ ព័ត៌មានភាគច្រើននៃរាជរដ្ឋាភិបាលគឺមានលក្ខណៈវិជ្ជមាន (របស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា) ដែលផ្តោតទៅលើការសាងសង់ ភាពរីកចម្រើននៃប្រទេសជាតិ ដែលស្ថិតនៅក្រោមការដឹកនាំរបស់សម្តេចទាំងបី (សម្តេច **ជា ស៊ីម** សម្តេច **ហេង សំរិន** សម្តេច **ហ៊ុន សែន** )។ **នាយករដ្ឋមន្ត្រី** គឺជាតួអង្គដ៏សំខាន់នៅក្នុងព័ត៌មាននយោបាយដោយត្រូវបានផ្សព្វផ្សាយ និងបានព្ញរហូតដល់ទៅ **១.០៨៣ លើក** ហើយភាគច្រើនគឺក្នុងន័យវិជ្ជមានសម្រាប់រដ្ឋាភិបាល ការដឹកនាំរបស់នាយករដ្ឋមន្ត្រី និងគណបក្សប្រជាជនកម្ពុជា។ ក្រៅពីការចាក់ផ្សាយសន្ទរកថាទាំងស្រុងរបស់នាយរកដ្ឋមន្ត្រី ពាក្យសម្តីសរសើរដល់នាយករដ្ឋមន្ត្រី ដូចជាក្រោមការ

---

[១] គិតដល់ថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០០៨។ ការអង្កេតពីម៉ោង ១២:០០ ដល់ ១៦:០០ និង ពីម៉ោង ១៨:០០ ដល់ ២០:០០។

[២] ព័ត៌មានទាក់ទងនឹងសមាជិកសភា សមាជិករាជរដ្ឋាភិបាល និងគណបក្សនយោបាយ។

ដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចនាយករដ្ឋមន្ត្រីបានធ្វើឱ្យប្រទេសជាតិរីកចម្រើននៅគ្រប់វិស័យ ត្រូវបានលើកឡើងដោយមន្ត្រីរាជរដ្ឋាភិបាលនានា ពេលចុះទៅកាន់មូលដ្ឋាន ហើយត្រូវបានផ្សព្វផ្សាយដោយ ទទក។

ចំណែកព័ត៌មានទាក់ទងនឹង**សកម្មភាពរបស់សភា** ទាំងរដ្ឋសភា និងព្រឹទ្ធសភា ត្រូវបានផ្សព្វផ្សាយដោយ ទទក **១០%** (**៤២០លើក**)។ ព័ត៌មានទាក់ទងនឹងសភាមានដូចជា កិច្ចប្រជុំសភាពេញអង្គ ការប្រជុំរបស់សមាជិកសភា ជាមួយគណៈប្រតិភូបរទេស សកម្មភាពចុះមូលដ្ឋានរបស់សមាជិករដ្ឋសភាជាដើម ដែលភាគច្រើនគឺមកពីគណបក្សប្រជាជនកម្ពុជា។

គណបក្ស **ប្រជាជនកម្ពុជា** នៅតែត្រូវបានផ្សាយ និងឮនៅក្នុង ទទក ច្រើនជាងគណបក្សដទៃទៀតដដែល។ គណបក្ស **ប្រជាជនកម្ពុជា** ត្រូវបានផ្សព្វផ្សាយ ឮ និងបង្ហាញក្នុង ទទក **៨៤%** (ស្មើនឹង **១៣៥លើក**) នៃការលើកឡើង ឬផ្សព្វផ្សាយពីគណបក្សនយោបាយទាំងអស់នៅក្នុង ទទក។ មានតែគណបក្ស **ប្រជាជនកម្ពុជា** តែមួយប៉ុណ្ណោះដែលសមិទ្ធផល ក៏ដូចជាជោគជ័យនានារបស់គណបក្សខ្លួនត្រូវបានផ្សព្វផ្សាយដោយ ទទក។ ដូចជាការផ្សព្វផ្សាយពី **មីទ្ទិញថ្ងៃទី ០៧ មករា** នៅទីស្នាក់ការគណបក្ស **ប្រជាជនកម្ពុជា** ដែលក្នុងពិធីនោះ ប្រធាន ក៏ដូចជាសមាជិកជាន់ខ្ពស់របស់គណបក្សនេះបានលើកឡើងពីគុណបំណាច់ **ក៏ដូចជាការអភិវឌ្ឍរបស់ប្រទេសជាតិ** ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា។ ក្នុងឱកាសដែលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រខិតជិតមកដល់ មន្ត្រីរាជរដ្ឋាភិបាល ជាពិសេស នាយករដ្ឋមន្ត្រី ដែលត្រូវបានផ្សព្វផ្សាយដោយ ទទក ជារឿយៗបានលើកឡើងពីគណបក្សរបស់ខ្លួនចំៗ (គណបក្សប្រជាជនកម្ពុជា) ដោយបានសរសើរ និងផ្សព្វផ្សាយពីសកម្មភាព ក៏ដូចជាសមិទ្ធផលរបស់គណបក្ស ហើយពេលខ្លះបាន រិះគន់ដល់គណបក្សនយោបាយដទៃទៀត ខណៈដែលគណបក្សដទៃទៀតមិនត្រូវបានផ្សព្វផ្សាយបែបនេះឡើយដោយ ទទក។ ទទក ក៏បានបង្ហាញនូវផ្លាកសញ្ញាគណបក្សប្រជាជនកម្ពុជាផងដែរ ដូចជានៅពេលមន្ត្រីរាជរដ្ឋាភិបាល ចុះចែកអំណោយ និងសួសុខទុក្ខជាដើម ដែលអំណោយនោះពេលខ្លះមានផ្លាកសញ្ញារបស់គណបក្ស( ប្រជាជនកម្ពុជា)។

គណបក្ស **ហ៊្វុនស៊ិនប៉ិច** ត្រូវផ្សព្វផ្សាយ ឮ និងបង្ហាញ **១៣%** (ស្មើនឹង **២១ លើក**)។ ការបង្ហាញពីគណបក្ស **ហ៊្វុនស៊ិនប៉ិច** ដោយទទក មានដូចជាក្នុងឱកាសគណបក្សនេះជួបជាមួយប្រតិភូគណបក្សរបស់ចិន និងវៀតណាមជាដើម និងពេលខ្លះត្រូវបានលើកឡើងដោយនាយករដ្ឋមន្ត្រី និងមន្ត្រីក្នុងរាជរដ្ឋាភិបាលមកពីគណបក្ស ហ៊្វុនស៊ិនប៉ិច។

គណបក្ស **សមរង្ស៊ី** ដែលជាគណបក្សនៅក្រៅរដ្ឋាភិបាលត្រូវបាន ឮឈ្មោះ **៥ដង** ដូចជាការផ្សាយរបស់ ទទក ចំពោះ ការគាំទ្ររបស់គណបក្សនយោបាយជាប់ឆ្នោតទាំង ៣ រួមទាំង គណបក្ស **សមរង្ស៊ី** ដែលគាំទ្រមិនឱ្យមានការដកអភ័យឯកសិទ្ធិរបស់អតីតព្រះមហាក្សត្រ **នរោត្តម សីហនុ**។

**កម្មវិធី ព័ត៌មានសមធមិប្រចាំសប្ដាហ៍**[៣]

កម្មវិធីព័ត៌មានសមធមិប្រចាំសប្ដាហ៍បានផ្ដល់ឱកាសតិចតួចដល់គណបក្សនយោបាយមួយចំនួន ជាពិសេសគណបក្សមានអសនៈនៅក្នុងសភា ក្នុងការមានលទ្ធភាពបង្ហាញខ្លួននៅក្នុងកម្មវិធីរបស់ខ្លួន។ ទោះបីយ៉ាងណា ការអង្កេតឃើញមានការផ្សាយទាក់ទងនឹងការបោះឆ្នោតខ្លះផងដែរ ដូចជាការផ្សាយពីការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការសម្ភាសន៍មន្ត្រីគណៈកម្មាធិការរៀបចំការបោះឆ្នោតទាក់ទងនឹងដំណើរការបោះឆ្នោតជាដើម។

ក្នុងអំឡុងពេលអង្កេតនេះ មានគណបក្សនយោបាយចំនួន ៤ ត្រូវបានបង្ហាញ ឬ ឮឈ្មោះ។ គណបក្ស **ប្រជាជនកម្ពុជា** និងគណបក្ស **សមរង្ស៊ី** ត្រូវបានផ្សព្វផ្សាយនៅក្នុងកម្មវិធីនេះចំនួន **៣ ដង** ខណៈដែលគណបក្ស **ហ៊្វុនស៊ិនប៉ិច** ចំនួន **២ ដង** និងគណបក្ស **នរោត្ដមរណឫទ្ធិ**ចំនួន **១ ដង**។ ឧទាហរណ៍ នៅក្នុងការផ្សាយពីការលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីឈ្មោះបោះឆ្នោត កម្មវិធីសមធមិប្រចាំសប្ដាហ៍បានសម្ភាសន៍តំណាងគណបក្សទាំង **៤ ខាងលើ** ជុំវិញដំណើរការនេះ។

សកម្មភាពសមាជិករដ្ឋសភាក៏ដូចជាការសម្ភាសន៍សមាជិករដ្ឋសភាទាក់ទងនឹងច្បាប់នានា ត្រូវបានផ្សាយនៅក្នុង **១១ កម្មវិធី**[៤] ដែលក្នុងនោះសមាជិកសភាមកពីគណបក្ស **សមរង្ស៊ី** ត្រូវបានបង្ហាញច្រើនជាងគេចំនួន **១១ ដង** សមាជិកសភាមកពីគណប្សប្រជាជនកម្ពុជា ចំនួន **៨ ដង** និងគណបក្ស **ហ៊្វុនស៊ិនប៉ិច** ចំនួន **៧ ដង**។ ចំណែកព័ត៌មានទាក់ទងនឹង**រាជរដ្ឋាភិបាល**ត្រូវបានផ្សព្វផ្សាយនៅក្នុង **១៧ កម្មវិធី**។

ជារួមការអង្កេតឃើញថា **កម្មវិធីសមធមិប្រចាំសប្ដាហ៍** ភាគច្រើននៅតែផ្ដោតទៅលើប្រធានបទបញ្ហាសង្គម ទំនៀមទំលាប់ ការរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍជាដើម។ ខុមហ្វ្រែលសូមជម្រុញឱ្យកម្មវិធីនេះផ្ដោតខ្លាំងថែមទៀតចំពោះព័ត៌មាននយោបាយ និងការអប់រំអ្នកបោះឆ្នោតដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងវិស័យនយោ-បាយ និងការបោះឆ្នោត ព្រោះថាដំណើរការបោះឆ្នោតនៅក្នុងប្រតិទិនបានចាប់ផ្ដើមហើយ ថ្ងៃបោះឆ្នោតក៏ខិតជិតមកដល់ហើយដែរ។

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១
- លោក **កុយ ច័ន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១

---

[៣] *រយៈពេលអង្កេតក្នុងរបាយការណ៍នេះគិតពីថ្ងៃទី ១២ សីហា ២០០៧ ដល់ ០៧ មករា ២០០៨។*

[៤] ក្នុងមួយកម្មវិធីអាចសម្ភាសន៍សមាជិកសភាមកពីគណបក្សលើសពីមួយគណបក្ស។